# សិល្បៈ វប្បធម៌នៃ ប្រទេសម៉ាល់តា

ម៉ាល់តា (Malta) គឺជាប្រទេសតូចមួយក្នុងទ្វីបអឺរ៉ុបដែលមានទីតាំងស្ថិតនៅកណ្តាលមហាសមុទ្រមីឌីទែរ៉ាណេ (Mediterranean) ដោយនៅជិតប្រទេសលីប៊ី (Libya) និងប្រទេសទុយនេស៊ី[១] (Tunisia)។ ប្រទេសនេះ ជាតំបន់ដ៏សំខាន់នៃផ្លូវពាណិជ្ជកម្មក្នុងបណ្តាញផ្លូវនៃមហាសមុទ្រ មីឌីទែរ៉ាណេ និងជាប្រទេសដែលសំបូរប្រេងកាតផងដែរ (រូបលេខ១-២)។

ម៉ាល់តាគឺជាប្រទេសដែលមានអាយុកាលដ៏ចំណាស់មួយ ពោលគឺមានការតាំងទីរស់នៅតាំងពី ៤០០០ឆ្នាំមុនគ.ស.មកម្ល៉េះ និងនៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសនេះ គឺមានការគ្រប់គ្រងដោយអាណាចក្រដ៏ទៃទៀតជាបន្តបន្ទាប់ ដូចជា ផូនេសេន (Phoenicians), ក្រិច (Greeks), កាតាច(Carthaginians), រ៉ូម៉ាំង (Romans), ប៊ីហ្សង់ទិន (Byzantines), អារ៉ាប់ (Arabs), បារាំងជាដើម និងនៅឆ្នាំ១៩៦៤។ ប្រទេសនេះបានទទួលឯករាជ្យពីចក្រភពអង់គ្លេស និងបន្តក្លាយជាសាធារណរដ្ឋ ម៉ាល់តា (Republic of Malta) នៅចាប់ពីឆ្នាំ១៩៧៤ រហូតដល់បច្ចុប្បន្ន។[២] ម៉ាល់តា គឺជាប្រទេសដែលមានប្រជុំកោះចំនួន៧ស្ថិតនៅកណ្តាលមហាសមុទ្រមីឌីទែរ៉ាណេ ដោយមានរាជធានីមួយឈ្មោះ ថា វ៉ាឡេតា (Valletta ) និងនៅទីនោះមានតំបន់ប្រាសាទចំនួនប្រាំពីរ ដែលត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកក្នុងឆ្នាំ ១៩៨០ (Seven Megalithic Temples of Malta)។ រាជធានី វ៉ាឡេតា ត្រូវបានកសាងឡើងនៅស.វ.ទី ១៦គ.ស. តាមរបៀបនៃឥទ្ធិពលរបស់លោកខាងលិច ជាពិសេស សំណង់ស្ថាបត្យកម្ម។[៣]

---

[១] [(PDF) Geology and early human history of the islands of Malta, Mediterranean Sea. (researchgate.net)]

[២] Ibid

[៣] [City of Valletta - UNESCO World Heritage Centre]

អត្ថបទដោយ៖ អេង តុលា

Seven Megalithic Temples of Malta គឺជាសំណង់ប្រាសាទកសាងនៅក្នុងសម័យបុរេប្រវត្តិក្នុងអំឡុង៤០០០ឆ្នាំមុនគ.ស. ទៅ ៣០០០ឆ្នាំមុនគ.ស.។[៤] ក្នុងចំណោមសំណង់ទាំងប្រាំពីរនោះ គឺមានប្រាសាទចំនួនពីរដែលល្បីល្បាញជាងគេ គឺប្រាសាទ Hagar Qim នៅលើកោះ ម៉ាល់តា និង Ggantija នៅលើកោះ កូសូ។

Hagar Qim គឺជាប្រាសាទដែលមានទីតាំងស្ថិតនៅផ្នែកខ្ពស់ជាងគេ នៃកោះ ម៉ាល់តា។ ប្រាសាទនេះ កសាងឡើងពីថ្ម តំរៀបពីលើគ្នារាងទ្រវែង និងមានទ្វារចូលនៅកណ្តាល។ រីឯសំណង់ប្រាសាទ Ggantija គឺជាសំណង់ប្រាសាទតែមួយគត់ដែលសាងសង់នៅលើខ្ពង់រាបកូសូ សាងសង់ឡើងនៅចន្លោះឆ្នាំ ៣៦០០ មុនគ.ស. រហូតដល់ឆ្នាំ ៣២០០មុនគ.ស.។[៥] នៅទីនោះ អ្នកស្រាវជ្រាវក៏បានរកឃើញនូវឆ្អឹងសត្វ ដែលបង្ហាញអំពីការគោរពសាសនាចំពោះ ប្រាសាទ Ggantija នេះ(រូបលេខ៣-៤)។

ប្រាសាទទាំង៧ដែលសាងសង់នៅក្នុងប្រទេសម៉ាល់តា គឺមានរចនាសម្ព័ន្ធផ្សេងៗគ្នា និងមានបច្ចេកទេសសាងសង់ក៏ផ្សេងៗគ្នាដែរ។ សំណង់ទាំងនោះ គឺសាងសង់អំពីថ្មដាក់តម្រៀបពីលើគ្នា និងមានកំពែងជុំវិញផងដែរ។

តាមរយៈនៃទិន្នន័យដែលបានបង្ហាញខាងលើ ម៉ាល់តា គឺជាប្រទេសដែលមានមនុស្សរស់នៅ និងមានសំណង់ស្ថាបត្យកម្មប្រាសាទដែលមានអាយុកាល ៤០០០ឆ្នាំ មុន គ.ស ពោលស្ថិតនៅក្នុងសម័យបុរេប្រវត្តិ។ ដោយឡែកនៅក្នុងសម័យកាលប្រវត្តិសាស្ត្រប្រទេសនេះ ក៏មានការគ្រប់គ្រងជាបន្តបន្ទាប់ពី អាណាចក្រ ដ៏ទៃទៀត និងបានបន្សល់ទុកនូវសិល្បៈ វប្បធម៌ តាមរយៈ សំណង់ស្ថាបត្យកម្មក្នុងទឹកដី នៃប្រទេសម៉ាល់តា។ ម៉ាល់តា គឺជាប្រទេសដែលសំបូរទៅធនធានធម្មជាតិ ជាពិសេស ធនធានរ៉ែប្រេងកាត ដែលធ្វើឱ្យ

---

៤ Megalithic Temples of Malta - UNESCO World Heritage Centre

៥ https://heritagemalta.mt/explore/ggantija-temples/

អត្ថបទដោយ៖ អេង តុលា

ប្រទេសនេះជាប់ជាប្រទេសអ្នកមានទី២៥ នៅក្នុងតារាងប្រទេសដែលមានជាងគេនៅក្នុងពិភពលោក។




រូបលេខ១ ៖ ផែនទីនៃប្រទេសម៉ាល់តា និង រូបលេខ២៖ ទីក្រុង Valletta

ប្រភព៖ britannica



អត្ថបទដោយ៖ អេង តុលា



រូបលេខ៣ ៖ ប្រាសាទ Hagar Qim

ប្រភព៖ https://heritagemalta.mt/explore/ggantija-temples/







រូបលេខ២៤ ៖ ប្រាសាទ Ggantija

ប្រភព៖ https://heritagemalta.mt/explore/ggantija-temples/

អត្ថបទដោយ៖ អេង តុលា

## ឯកសារយោង

(PDF) Geology and early human history of the islands of Malta, Mediterranean Sea. (researchgate.net)

City of Valletta - UNESCO World Heritage Centre

Megalithic Temples of Malta - UNESCO World Heritage Centre

https://heritagemalta.mt/explore/ggantija-temples/

អត្ថបទដោយ៖ អេង តុលា